**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០៦១ ទសក

ថ្ងៃព្រហស្បតិ៍ ៤កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ២០២១

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់ការបើកដំណើរការ គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឡើងវិញរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១**._

ត្រូវបានដាក់ឱ្យអនុវត្ត "នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី" ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវអនុវត្តបន្ថែមតាមការណែនាំរបស់រដ្ឋបាលរាជធានី ខេត្តក្នុងករណីមានការរឹតបន្តឹងការអនុវត្តវិធានការរដ្ឋបាល។

**ប្រការ២**._

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃសេចក្ដីសម្រេចនេះត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ៣**._

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្តត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៣៤

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល៖
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានី-ខេត្ត
-មន្ទីរទេសចរណ៍រាជធានី-ខេត្ត
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា

# សម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាល

# ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច

# សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

# និងមជ្ឈមណ្ឌលវាយតម្លៃ

# ក្នុងគន្លងប្រក្រតីភាពថ្មី

ឆ្នាំ ២០២១

# នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី

ដើម្បីលើកកម្ពស់ និងធានាដល់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ប្រកបដោយប្រសិទ្ធភាពតាមបែបគន្លងប្រក្រតីភាពថ្មី គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវអនុវត្តតាម "នីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី" ដូចខាងក្រោម៖

## ១. ការអភិបាលកិច្ច ក្របខ័ណ្ឌច្បាប់ និងយន្តការ

- ត្រូវបានបង្កើត និងពង្រឹងភារកិច្ចរបស់ក្រុមការងារតាមដាន និងត្រួតពិនិត្យសុខភាពនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ដោយមានការកំណត់សមាសភាព និងភារកិច្ចច្បាស់លាស់។
- ត្រូវដាក់បញ្ចូល និងពង្រឹងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាព ដែលបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ។
- គោរពតាមការណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល វិធានការ និងគោលការណ៍របស់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ ទាក់ទងនឹងវិធានការបង្ការ និងការពារជំងឺឆ្លងកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗ ព្រមទាំងសហការឱ្យបានខ្ជាប់ខ្ជួនជាមួយមន្ត្រីជំនាញរបស់ក្រសួង និងស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការចុះត្រួតពិនិត្យក្នុងករណីចាំបាច់។
- ត្រូវលើកកម្ពស់ការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមា សម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ដែលក្រសួងទេសចរណ៍បានដាក់ចេញកន្លងមកប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

## ២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសិក្សា

### ២.១. ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងផាសុកភាព

- ត្រូវរក្សាសីតុណ្ហភាពក្នុងបន្ទប់រៀន និងនៅតាមទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារមិនឱ្យទាបជាង២៤អង្សាសេ។

- ត្រូវអនុវត្តវិធានសម្លាប់មេរោគមុននឹងដាក់ឱ្យដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ជាពិសេស បន្ទប់រៀន បណ្ណាល័យ ទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ អាហារដ្ឋាន បន្ទប់គ្រូ បន្ទប់បុគ្គលិក បន្ទប់ទឹក កន្លែងលាងសម្អាតដៃ អគារ សួនកម្សាន្ត ចំណតយានយន្ត និងសម្ភារៈបរិក្ខាបណ្តុះបណ្តាលដែលចាំបាច់ផ្សេងៗ។
- ត្រូវរៀបចំអនាម័យបោសសម្អាតបន្ទប់សិក្សា អគារនៅក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃឱ្យបានជាប់ជាប្រចាំ។
- ត្រូវទុកដាក់សំរាម និងកាកសំណល់ឱ្យបានត្រឹមត្រូវជាប្រចាំ និងបាញ់ថ្នាំសម្លាប់មេរោគ មុននឹងយកទៅចោលក្នុងធុងសំរាម។
- ត្រូវសម្អាត ឬសម្លាប់មេរោគឱ្យបានញឹកញាប់នៅតាមកន្លែងសិក្សា ឬនៅលើផ្ទៃវត្ថុ ដែលអាចមានមនុស្សច្រើនប៉ះពាល់ដូចជា ដៃទ្វារ តុ កៅអី និងសម្ភារៈបរិក្ខាបណ្តុះបណ្តាលនៅតាមទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ។
- ត្រូវបើកទ្វារ បង្អួច ឬវាំងនន ឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា និងម៉ោងហ្វឹកហាត់ការងារផ្ទាល់។
- ត្រូវពាក់ម៉ាស់ ស្រោមដៃ របាំងមុខ មួកគ្របសក់ និងស្បែកជើង ឱ្យបានត្រឹមត្រូវមុនពេល និងក្នុងពេលសម្អាតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ចំពោះអ្នកដែលទទួលខុសត្រូវក្នុងការសម្អាត។
- ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ការសម្អាតអនាម័យនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃដើម្បីធានាថាពុំមានការចម្លងជំងឺកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗ ទៅដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការងារផ្សេងទៀតជាដាច់ខាត។

## ២.២. ការណែនាំស្តីពីការអនុវត្តក្នុងបរិវេណមុខ និងក្នុងទីតាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ

- កំណត់ទិសដៅផ្ទុយគ្នាសម្រាប់ច្រកដែលអ្នកសិក្សាចូលទៅក្នុងសាលា និងពេលចេញមកវិញ ដោយមានការដាក់តាំងសញ្ញាច្បាស់លាស់។
- មានបុគ្គលិកបណ្តុះបណ្តាលប្រចាំការ ឬបំពាក់ម៉ាស៊ីនត្រួតពិនិត្យកម្តៅដោយស្វ័យប្រវត្តិ និងបញ្ជូនសញ្ញានៅច្រកចេញចូលដែលតម្រូវឱ្យមានការវាស់កម្តៅមុនចូលឱ្យបានគ្រប់ៗគ្នា។

- មានបុគ្គលិកបណ្តុះបណ្តាលប្រចាំការ ឬបំពាក់ម៉ាស៊ីនបាញ់អាកុល ឬថ្នាំសម្លាប់មេរោគដោយស្វ័យប្រវត្តិ ស្របតាមស្តង់ដាត្រឹមត្រូវនៅច្រកចេញចូល និងតម្រូវឱ្យមានការលាងដៃ ឬឆ្លងកាត់ម៉ាស៊ីនសម្លាប់មេរោគគ្រប់ៗគ្នាមុននឹងចូលទៅក្នុងទីតាំងបរិវេណសិក្សា។
- មានបុគ្គលិកបណ្តុះបណ្តាលប្រចាំការ ស្លាកសញ្ញាណែនាំ និងតម្រូវឱ្យជនគ្រប់រូបដែលចូលក្នុងទីតាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃធ្វើការកត់ត្រាវត្តមាន ឬតម្រូវឱ្យចុះឈ្មោះក្នុងប្រព័ន្ធ QR CODE ដើម្បីទប់ស្កាត់កូវីដ-១៩(www.StopCovide19.gov.kh) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- តុអង្គុយសម្រាប់អ្នកសិក្សាក្នុងបន្ទប់សិក្សា ទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ ត្រូវរក្សាគម្លាតសុវត្ថិភាព ១,៥០ ម៉ែត្រឡើងទៅ និងមានចំណុះថ្នាក់ដោយកំណត់អ្នកសិក្សាមិនឱ្យលើសពី ២០នាក់ ក្នុង០១ថ្នាក់។ ករណីបន្ទប់មានទំហំធំទូលាយ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ អាចរៀបចំតុកៅអីអង្គុយសម្រាប់អ្នកសិក្សាលើសពី ២០នាក់ ដោយអនុវត្តតាមគម្លាតសុវត្ថិភាព និងវិធានការសុខាភិបាល។
- ត្រូវបើកទ្វារច្រកចេញចូលក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំ មនុស្សច្រើនកកកុញ តាមច្រកទ្វារចេញចូល ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី ១,៥០ ម៉ែត្រឡើងទៅ និងត្រូវមានការដាក់សញ្ញាកំណត់ច្បាស់លាស់។
- ត្រូវរៀបចំការគោរពទង់ជាតិក្នុងទ្រង់ទ្រាយតូចជាតំណាង ដើម្បីរក្សាគម្លាតសុវត្ថិភាព ដោយធ្វើការផ្លាស់វេនតាមថ្នាក់នីមួយៗ។
- ត្រូវធ្វើការបែងចែកអ្នកសិក្សា ដោយមានមួយចំនួននៅក្នុងថ្នាក់ និងមានមួយចំនួនទៀតចេញក្រៅបន្ទប់សិក្សានៅពេលម៉ោងចេញលេងម្តងៗ។
- ត្រូវបិទស្លាកសញ្ញាសម្គាល់ទីតាំង ត្រូវឈរតម្រង់ជួរចេញចូលបន្ទប់ទឹក និងត្រូវរក្សាគម្លាតសុវត្ថិភាព ១,៥០ ម៉ែត្រឡើងទៅ។
- ត្រូវបិទផ្សាយខ្លឹមសារជូនដំណឹងជាមុន នៅក្នុងបន្ទប់ទឹក អំពីកាតព្វកិច្ចពាក់ម៉ាស់ និងរក្សាគម្លាត និងរៀបចំកន្លែងលាងដៃឱ្យបានត្រឹមត្រូវជាប្រចាំ។
- ត្រូវរៀបចំកាលវិភាគចេញពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃម្តងមួយថ្នាក់ៗតាមលំដាប់លំដោយនៅពេលចប់ម៉ោងសិក្សាត្រូវត្រឡប់ចេញទៅផ្ទះរៀងៗខ្លួន។
- ត្រូវធានាសុវត្ថិភាពសម្រាប់សកម្មភាពដូចជា ការអនុវត្តការងារនៅតាមទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ ការប្រើប្រាស់សម្ភារៈបរិក្ខារបណ្តុះបណ្តាល និងសកម្មភាពកីឡា ការពិភាក្សាក្រុម ដោយត្រូវមានការដាក់សញ្ញាកំណត់ដើម្បីរក្សាគម្លាតសុវត្ថិភាព។

- ត្រូវផ្អាកដំណើរការបណ្ណាល័យ និងមិនត្រូវឱ្យមានការខ្ចីសៀវភៅពីគ្នាទៅវិញទៅមក ប្រសិនបើមានការរកឃើញជំងឺកូវីដ-១៩ និងត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅក្នុងបណ្ណាល័យជាមុនសិន មុននឹងអនុញ្ញាតឱ្យមានការបើកដំណើរការឡើងវិញ។
- ត្រូវបិទទ្វារបងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ព្រមទាំងចាត់តាំងការយាមកាមឱ្យបានហ្មត់ចត់អំឡុងពេលម៉ោងសិក្សា ដោយមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញចូលឡើយ។
- រាល់ការប្រមូលផ្តុំគ្រប់រូបភាព ទាំងអំឡុងពេលម៉ោងសិក្សា ឬក្រៅម៉ោងសិក្សា នៅតាមបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃត្រូវរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច ១,៥០ម៉ែត្រ ដោយកម្រិតចំនួនឱ្យបានជាអប្បបរមា។
- រាល់ការរៀបចំកម្មវិធីផ្សេងៗ ឬការជួបជុំណាមួយ នៅក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវអនុវត្តតាមវិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចៀសវាងនូវហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗ។

## ២.៣. ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាល

- អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល ដែលបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃទាំងអស់ត្រូវមានកាតព្វកិច្ចចាក់វ៉ាក់សាំង បង្ហាញនូវប័ណ្ណវ៉ាក់សាំងដល់បុគ្គលិកប្រចាំការនៅមុខច្រកចូល(បង្ហាញតែ០១លើក)។
- ដើម្បីធានាដល់ការវាយតម្លៃ និងតាមដានពីកាតព្វកិច្ចវ៉ាក់សាំងរបស់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាលដែលបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល ត្រូវធ្វើការចុះឈ្មោះ និងផ្តល់ទិន្នន័យទាក់ទងនឹងកាតព្វកិច្ចវ៉ាក់សាំងទៅក្នុងប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ www.tptd.org តាមរយៈតំណភ្ជាប់ https://www.tptd.org។
- ត្រូវចាត់វិធានការវាស់កម្តៅដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលា

បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃជាប្រចាំ មុនពេលអនុញ្ញាតឱ្យចូលក្នុងបរិវេណសិក្សាឡើយ។ ក្នុងករណីរកឃើញមានកម្តៅចាប់ពី ៣៧,៥អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណសិក្សាឡើយ ហើយត្រូវធ្វើការណែនាំ និងត្រូវអនុញ្ញាតឱ្យពួកគេសម្រាកនៅផ្ទះ ឬទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព។

- បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល ត្រូវឆ្លងកាត់ការបណ្តុះបណ្តាល ឬទទួលបានការណែនាំអំពីខ្លឹមសារវិធានការ "៣កុំ ៣ការពារ" និងវិធានការផ្សេងៗដែលបានដាក់ចេញដោយក្រសួងសុខាភិបាល ព្រមទាំងក្រសួង និងស្ថាប័នពាក់ព័ន្ធដទៃទៀត។
- ត្រូវពិនិត្យលទ្ធភាពរៀបចំបន្ទប់សុខភាព និងចាត់តាំងឱ្យមានជនបង្គោលទទួលបន្ទុកសុខភាព នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃនីមួយៗសម្រាប់ការសង្គ្រោះបឋម និងត្រូវមានឧបករណ៍តេស្តរហ័ស(Covid-19 Rapid Test) ដើម្បីពិនិត្យជូនអ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតដែលកំពុងបម្រើការងារ ដែលមានការសង្ស័យពាក់ព័ន្ធជាមួយការចម្លងជំងឺកូវីដ-១៩។
- ត្រូវណែនាំឱ្យអ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ បំពេញនូវព័ត៌មានសុខភាព និងប្រវត្តិនៃការធ្វើដំណើរមកពីក្រៅប្រទេស ដើម្បីពិនិត្យតាមដាន និងរក្សាទុកឯកសារ។
- ត្រូវណែនាំមាតាបិតា អាណាព្យាបាលសិស្សក្នុងការចូលរួមផ្តល់នូវព័ត៌មានអំពីសុខភាព និងប្រវត្តិនៃការធ្វើដំណើរក្នុង និងក្រៅប្រទេស និងការជួបជុំដែលអាចបង្កើតហានិភ័យនៃការឆ្លងនូវជំងឺកូវីដ-១៩។
- ត្រូវអនុញ្ញាតឱ្យអ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃឈប់សម្រាក ក្នុងករណីពួកគេមានអាការៈណាមួយដូចជា ក្តៅខ្លួនចាប់ពី ៣៧,៥ អង្សាសេឡើងទៅ ក្អក ហៀរសំបោរ ឈឺបំពង់ក ពិបាកដកដង្ហើម មានជំងឺផ្លូវដង្ហើម មានរោគសញ្ញាផ្សេងៗទៀតនៃជំងឺឆ្លង ឬជំងឺឆ្លងរាតត្បាតនានា ឬអ្នកដែលមានប្រវត្តិធ្វើដំណើរមកពីក្រៅប្រទេស ឬអ្នកធ្លាប់ប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ ដែលមិនទាន់បានធ្វើចត្តាឡីស័កពី១៤-២១ថ្ងៃ។

## ២.៤. ការរៀបចំអន្តេវាសិកដ្ឋាន និងទីតាំងទទួលទានអាហារ

- ត្រូវសម្អាត និងអនុវត្តវិធានការសម្លាប់មេរោគ នៅតាមបន្ទប់ស្នាក់នៅ និងឧបករណ៍បរិក្ខារប្រើប្រាស់របស់អ្នកសិក្សា រៀងរាល់ ០១សប្តាហ៍ម្តង។
- ត្រូវបើកទ្វារបង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលបន្ទប់ស្នាក់នៅបានគ្រប់គ្រាន់។

- អ្នកសិក្សា ក្នុងអំឡុងពេលស្នាក់នៅ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជាផ្ទៃក្នុងរបស់អន្តេវាសិកដ្ឋាន
- អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាលដែលយកចំណីអាហារពីផ្ទះរៀងៗខ្លួន ដើម្បីយកមកទទួលទាននៅទីតាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃដោយរក្សាអនាម័យ និងសុវត្ថិភាពសុខភាព។
- ត្រូវរៀបចំសណ្តាប់ធ្នាប់កន្លែងទទួលទានចំណីអាហារប្រកបដោយអនាម័យជាប់ជាប្រចាំ និងត្រូវកំណត់ឱ្យអ្នកទទួលទានអាហារទាំងអស់ស្ថិតនៅឃ្លាតពីគ្នាចាប់ពី ១,៥០ម៉ែត្រឡើងទៅ ដោយមិនត្រូវអនុញ្ញាតឱ្យអ្នកញ៉ាំអាហាររួមគ្នា ឬចែករំលែកចំណីអាហារគ្នាទៅវិញទៅមក ឬអង្គុយញ៉ាំចំណីអាហារកកកុញក្បែរគ្នានោះឡើយ ចៀសវាងការនិយាយច្រើន និងមិនត្រូវជជែកគ្នាដែលបង្ករសំលេងលឺខ្លាំងៗ។
- សម្រាប់ចំណីអាហារដែលផ្គត់ផ្គង់ដោយស្ថាប័នបណ្តុះបណ្តាលត្រូវមានអនាម័យ និងសុវត្ថិភាពខ្ពស់។ ចំពោះអ្នកទទួលទានដែលឈរចាំចាប់ ឬដូសម្លប ត្រូវតម្រង់ជាជួរ និងរក្សាគម្លាតពីគ្នាចាប់ពី ១,៥០ ម៉ែត្រឡើងទៅ ដោយមានការដាក់សញ្ញាកំណត់ច្បាស់លាស់។

## ២.៥. ការគ្រប់គ្រងទឹកស្អាត និងបរិក្ខារអនាម័យ

- ត្រូវពិនិត្យលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិ-សណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ជូនដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងត្រូវលើកទឹកចិត្តឱ្យនាំយកទឹកស្អាតពីផ្ទះ សម្រាប់ទុកទទួលទានផ្ទាល់ខ្លួន។
- ត្រូវរៀបចំបរិក្ខារលាងដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ ឬនៅក្បែរបន្ទប់សិក្សា ដោយត្រូវមានសាប៊ូ ទឹកស្អាត និងទឹកអាល់កុល ឬជែលអាល់កុល សមស្របតាមតម្រូវការរបស់អ្នកសិក្សា គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ។
- ត្រូវរៀបចំបរិក្ខារលាងដៃជាបណ្តោះអាសន្ន ចំពោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ដែលមិនទាន់មានបរិក្ខារលាងសម្អាតដៃ និងត្រូវដាក់វេនសម្អាតឱ្យបានត្រឹមត្រូវជាប្រចាំថ្ងៃ។
- ត្រូវពិនិត្យលទ្ធភាពរកទឹកសម្លាប់មេរោគដូចជា ទឹកអាល់កុល ឬជែលលាងសម្អាតដៃសម្រាប់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃឱ្យបានប្រើប្រាស់ប្រចាំថ្ងៃ។

- ត្រូវថែទាំបង្គន់អនាម័យជាប្រចាំដោយទឹកសាប៊ូ និងត្រូវបើកឱ្យប្រើប្រាស់រៀងរាល់ម៉ោងសិក្សាព្រមទាំងត្រូវបែងចែកឱ្យដាច់ពីគ្នារវាងបន្ទប់ទឹកប្រុស និងបន្ទប់ទឹកស្រី ហើយត្រូវដាក់វេនសម្អាតឱ្យបានច្រើនដងក្នុងមួយថ្ងៃ។

## ២.៦. ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធានៃការបង្ការជំងឺកូវីដ-១៩

- ត្រូវបិទផ្សាយរូបភាពផ្ទាំងធំ និងខិត្តប័ណ្ណអប់រំសុខភាពនានា ជាពិសេសរបៀបលាងសម្អាតដៃ វិធីការពារបង្ការជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ បានច្រើនកន្លែងដែលអាចមើលឃើញ និងអាចយកទៅអនុវត្តបាន។
- ត្រូវបើកវគ្គបណ្តុះបណ្តាលអំពីវិធានសុវត្ថិភាពដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាលឱ្យបានគ្រប់ៗគ្នាស្តីពីសារៈសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ-១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ។
- ត្រូវរៀបចំ និងពង្រឹងការអប់រំផ្សព្វផ្សាយខ្លឹមសារសុខភាពសំខាន់ៗ ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ឬជំងឺឆ្លងស្រួចស្រាវនានាដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល នៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ។
- ត្រូវតាមដាន និងប្រើប្រាស់ប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់ និងផ្លូវការ ស្តីពីស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដូចជាក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក។
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ឱ្យចេះគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ ដោយមិនត្រូវស្ថិតក្រោមទស្សនៈនៃការភ័យខ្លាច និងការរើសអើង ដែលអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ។
- ត្រូវកត់ត្រា និងតាមដានមូលហេតុអវត្តមានរបស់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ។ ក្នុងករណីសង្ស័យថា មានជំងឺផ្លូវដង្ហើម ឬជំងឺឆ្លងនានា ត្រូវជូនដំណឹងទៅមន្ត្រីក្រសួងសុខាភិបាល និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធដើម្បីចុះអន្តរាគមន៍។
- ត្រូវធ្វើការហាមឃាត់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាល មិនឱ្យធ្វើដំណើរទៅកន្លែងដែលមានអត្រាឆ្លងជំងឺកូវីដ-១៩ និងមិនត្រូវរៀបចំសកម្មភាពណាដែលអាចបង្កឱ្យមានហានិភ័យនៃការចម្លងរោគឡើយ។

- ត្រូវឱ្យអ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការនៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ អនុវត្តវិធានការអនាម័យជាប់ជាប្រចាំដោយការលាងសម្អាតដៃឱ្យបានញឹកញាប់ជាមួយទឹក និងសាប៊ូយ៉ាងតិច ៤០វិនាទីក្នុងពេលសម្អាតម្តងៗ ជាពិសេសនៅមុនពេលចូលរៀន ពេលចេញលេង និងពេលចេញទៅផ្ទះ។
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ឱ្យរៀបចំ និងយកជាប់តាមខ្លួនជានិច្ចនូវទឹកអាល់កុល ឬជែលអាល់កុលលាងដៃសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ព្រមទាំងម៉ាស់ការពារ នៅគ្រប់ពេលចេញពីផ្ទះ ពេលបំពេញការងារ ពេលធ្វើដំណើរ និងនៅក្នុងបរិវេណសិក្សា។
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ឬអ្នកដទៃទៀត ដែលចូលទំនាក់ទំនងជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវអនុវត្តការញើសសំបោរ ការខាកស្តោះឱ្យបានត្រឹមត្រូវ នៅក្នុងបន្ទប់ទឹក ឬបង្គន់អនាម័យ ដោយមិនអនុញ្ញាតដាច់ខាតការញើសសំបោរ ឬខាកស្តោះនៅក្នុងបន្ទប់រៀន បន្ទប់ប្រជុំ បណ្ណាល័យ ទីកន្លែងអនុវត្ត និងទីកន្លែងហ្វឹកហាត់ការងារ ឬក្នុងបរិវេណសិក្សាឡើយ។
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតធ្វើការខ្ទប់មាត់ និងច្រមុះពេលក្អក ឬកណ្តាស់ដោយប្រើគន្លាក់កែងដៃ ឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ។
- ត្រូវហាមឃាត់អ្នកសិក្សា គ្រូបណ្តុះបណ្តាល បុគ្គលិកបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតប៉ះពាល់គ្នាដោយផ្ទាល់ដូចជា ការចាប់ដៃ ឬប្រើប្រាស់របស់របរួមគ្នា និងត្រូវលើកកម្ពស់ការគោរពគ្នាដោយការសំពះតាមទំនៀមទម្លាប់ខ្មែរ។
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកផ្សេងទៀតចៀសវាងការប៉ះពាល់ជាមួយអ្នកជំងឺ (គ្រុនក្តៅ ក្អកហៀរសំបោរ ផ្តាសាយ) ក្នុងករណីគ្មានសម្ភារៈការពារខ្លួន និងមិនត្រូវយកដៃប៉ះភ្នែក ច្រមុះ និងមាត់ឡើយ។
- ត្រូវណែនាំអ្នកបើកបររថយន្តដឹកអ្នកសិក្សា ឱ្យពាក់ម៉ាសការពារជាប់ជាប្រចាំនៅពេលបើកបរ ត្រូវបើកបង្អួច ឬវាំងនន ឱ្យខ្យល់ចេញចូលបានល្អ និងត្រូវរក្សាគន្លាតកន្លែងអង្គុយដោយទុកចន្លោះ ០១កៅអី។
- ត្រូវពិនិត្យកម្តៅអ្នកសិក្សា មុនពេលអនុញ្ញាតឱ្យឡើងជិះរថយន្ត ឬមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត។ ប្រសិនបើឃើញថាមានកម្តៅលើសពី ៣៧,៥ អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យអ្នកសិក្សាឡើងជិះ

ឡើយ។ មុនពេលឡើងទៅលើថេយន្ត ត្រូវឱ្យអ្នកសិក្សា និងអ្នកបើកបរ លាងសម្អាតដៃនឹងទឹកអាល់កុល ឬជែលអាល់កុល រយៈពេល ២០វិនាទី ជាមុនសិន និងធ្វើការបាញ់សម្អាតសម្លាប់មេរោគក្នុងរថយន្តជាប់ជាប្រចាំ។

- ត្រូវផ្តល់ការគាំទ្រផ្នែកសង្គមដល់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល ដើម្បីឱ្យពួកគេចេះទប់ទល់នឹងជំងឺធ្លាក់ទឹកចិត្ត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ ដូចជាការរស់នៅដាច់ដោយឡែក និងការរស់នៅក្នុងទីកន្លែងដែលមានការរាតត្បាតនៃជំងឺកូវីដ-១៩។
- ត្រូវទទួលបានការវាយតម្លៃពីក្រុមការងារនៃនាយកដ្ឋានជំនាញរបស់ក្រសួងទេសចរណ៍ ក្នុងការចុះពិនិត្យនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ដើម្បីធានាការអនុវត្តឱ្យមានប្រសិទ្ធភាព។

## ៣. ការចូលរួមពីស្ថាប័នជំនាញពាក់ព័ន្ធនានា

### ៣.១. អង្គភាពបណ្តុះបណ្តាល

- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃត្រូវសហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ក្នុងការតាមដាន និងវាយតម្លៃការអនុវត្ត **"នីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី"** រៀងរាល់ ០៣ខែម្តង និងអាចក្នុងអំឡុងពេលសមស្របណាមួយ ក្នុងករណីពិនិត្យឃើញថាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃណាមួយពុំបានអនុវត្តត្រឹមត្រូវតាមនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមានេះ។
- ករណីដែលគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ អនុវត្តមិនបានត្រឹមត្រូវ និងមិនផ្តល់កិច្ចសហការជាមួយនឹងនាយកដ្ឋានជំនាញ និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ នោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ នឹងត្រូវប្រឈមវិធានការច្បាប់ និងវិធានការរដ្ឋបាលតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ៣.២. អាជ្ញាធរមូលដ្ឋាន

- ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការទទួលព័ត៌មានពីហានិភ័យដែលអាចកើតមានឡើងពីការចេញចូលនៃអ្នកសិក្សា អ្នកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងព័ត៌មានពីការគ្រប់គ្រងអ្នកចំណូលថ្មី ឬព័ត៌មានពីការជួបជុំនានា ដែលសង្ស័យពាក់ព័ន្ធនឹងការបង្កហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ ក្នុងបរិវេណសិក្សា។

### ៣.៣. ស្ថាប័នសុខាភិបាល

- ត្រូវពង្រឹងកិច្ចសហការជាមួយស្ថាប័នសុខាភិបាលគ្រប់លំដាប់ថ្នាក់ ក្នុងករណីសង្ស័យពីការចម្លងជំងឺកូវីដ-១៩ ត្រូវធ្វើអន្តរាគមន៍បន្ទាន់ និងទាក់ទងទៅលេខ១១៥ ក្នុងករណីសង្ស័យមានអ្នកជំងឺកូវីដ-១៩ ឬជំងឺឆ្លងរាតត្បាតផ្សេងទៀតនៅក្នុងបរិវេណសិក្សា។
- សហការជាមួយមន្ត្រីសុខាភិបាលលក្ខណៈជាប្រព័ន្ធ ដើម្បីគាំទ្រ និងតាមដានសុខភាពរបស់អ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និងបុគ្គលិកបម្រើការងារផ្សេងទៀត ក្នុងករណីមានការឆ្លងជំងឺផ្សេងៗ។

## ៤. ដំណើរការនៃការរាយការណ៍

### ៤.១. ករណីអ្នកសិក្សា បុគ្គលិកបណ្តុះបណ្តាល និងគ្រូបណ្តុះបណ្តាលមានកម្តៅខ្ពស់

- ករណីមានការពិនិត្យឃើញថា អ្នកសិក្សា បុគ្គលិកសិក្សា និងគ្រូបណ្តុះបណ្តាលមានកម្តៅលើសពី ៣៧,៥ អង្សាសេ អ្នកទាំងនោះមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវធ្វើការរាយការណ៍ជាបន្ទាន់ទៅកាន់ស្ថាប័នមានសមត្ថកិច្ច។ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវរៀបចំឱ្យមានតារាងលេខទូរស័ព្ទទំនាក់ទំនងរបស់ស្ថាប័នមានសមត្ថកិច្ច ដាក់បិទបង្ហាញនៅក្នុងបរិវេណសិក្សា។

### ៤.២. ការចូលរួមឆ្លើយតបជំងឺកូវីដ-១៩

- ត្រូវផ្តល់ឈ្មោះជនបង្គោល និងលេខទូរស័ព្ទទំនាក់ទំនងរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ សម្រាប់ផ្តល់ព័ត៌មានទំនាក់ទំនងជាមួយមន្ត្រីជំនាញសុខាភិបាល និងស្ថាប័នមានសមត្ថកិច្ច ដើម្បីងាយស្រួលទាក់ទងគ្នា ចូលរួមអង្កេតស្រាវជ្រាវតាមវិធានការរបស់ក្រសួងសុខាភិបាល និងរួមសហការយ៉ាងជិតស្និទ្ធ និងប្រកបដោយតម្លាភាព ព្រមទាំងផ្តល់ព័ត៌មានដែលត្រូវការដោយមន្ត្រីជំនាញសុខាភិបាល។

### ៤.៣. ការរៀបចំរបាយការណ៍

- ក្រុមការងារពិនិត្យតាមដានសុខភាពនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ត្រូវរៀបចំរបាយការណ៍ប្រចាំខែស្តីពីដំណើរការរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ឱ្យបានទៀងទាត់មកក្រសួងទេសចរណ៍ និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

# ឧបសម្ព័ន្ធ
# នៃនីតិវិធីប្រតិបត្តិស្តង់ដារអប្បបរមាសម្រាប់ការបើកដំណើរការ
# គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
# សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
# និងមជ្ឈមណ្ឌលវាយតម្លៃ
# ក្នុងគន្លងប្រក្រតីភាពថ្មី

# ឧបសម្ព័ន្ធទី០១

# សមាសភាព និងតួនាទីភារកិច្ចរបស់
# ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃការបើកដំណើរការ
# សម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
# សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍
# និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី

**សមាសភាព៖**

| | | |
|---|---|---|
| ១. ឯកឧត្តម **ណេប សាមុត** | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ | ប្រធាន |
| ២. ឯកឧត្តម **ឆាយ យុនឡុង** | អគ្គនាយករងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ | អនុប្រធាន |
| ៣. លោក **មាន វ៉ាន់ដេត** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម លោក-លោកស្រី | ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត | សមាជិក |
| ៥. លោក **ចឹក តារុណ** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ៦.លោក **គឹម ប៊ុនណារ៉ា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ៧. លោក **ស្រី សំនិត** | ប្រធានការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ៨. លោក **សាំង ចន្ទ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ៩. លោក **គឹម ពន្លឺ** | អនុប្រធានការិយាល័យនៃនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ១០. លោក **ទន់ បញ្ញា** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ១១. លោក **ផារ៉ាក់ ច័ន្ទរតនា** | មន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |

**ក្រុមការងារនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- ត្រួតពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំបើកដំណើរការឡើងវិញសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី។
- ជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី និងវិធានការផ្សេងៗទាក់ទងនឹងការលើកកម្ពស់សុខភាព និងការបង្ការជំងឺឆ្លងផ្សេងៗរបស់ក្រសួងសុខាភិបាល ព្រមទាំងក្រសួង និងស្ថាប័នពាក់ព័ន្ធនានា។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមាសម្រាប់ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្នុងគន្លងប្រក្រតីភាពថ្មី។
- ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងការផ្អាកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ។
- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

## ឧបសម្ព័ន្ធទី០២
## តារាងត្រួតពិនិត្យសម្រាប់វាយតម្លៃ

### ១ .ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសិក្សា (២៦០ពិន្ទុ)

#### ១.១. ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងផាសុកភាព

| ល.រ | សូចនាករនៃការអនុវត្ត | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១.១.១ | រក្សាសីតុណ្ហភាពក្នុងបន្ទប់រៀន និងនៅតាមទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារមិនឱ្យទាបជាង ២៤អង្សាសេ។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.១.២ | អនុវត្តវិធានសម្លាប់មេរោគមុននឹងដាក់ឱ្យដំណើរការ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ជាពិសេស បន្ទប់រៀន បណ្ណាល័យ ទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ អាហារដ្ឋាន បន្ទប់គ្រូ បន្ទប់បុគ្គលិក បន្ទប់ទឹក កន្លែងលាងសម្អាតដៃ អគារ សួនកម្សាន្ត ចំណតយានយន្ត និងសម្ភារៈបរិក្ខារបណ្តុះបណ្តាលដែលចាំបាច់ផ្សេងៗ។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.១.៣ | រៀបចំបោសសម្អាតបន្ទប់សិក្សា និងអគារនៅក្នុងបរិវេណគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃបានជាប់ជាប្រចាំ។ | ☐ មាន<br>☐ មិនមាន | ៥ |
| ១.១.៤ | ធ្វើការសម្អាត ឬសម្លាប់មេរោគញឹកញាប់នៅតាមកន្លែងសិក្សា ឬនៅលើផ្ទៃវត្ថុ ដែលអាចមានមនុស្សច្រើនប៉ះពាល់ ដូចជា ដៃទ្វារ តុ កៅអី និងសម្ភារៈបរិក្ខារបណ្តុះបណ្តាលនៅតាមទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.១.៥ | បើកទ្វារ បង្អួច ឬវាំងននបានធំទូលាយដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា និងម៉ោងហ្វឹកហាត់ការងារផ្ទាល់។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.១.៦ | ពាក់ម៉ាស់ ស្រោមដៃ របាំងមុខ មួកគ្របសក់ និងស្បែកជើងបានត្រឹមត្រូវ មុនពេល និងក្នុងពេលសម្អាតចំពោះអ្នកដែលទទួលខុសត្រូវក្នុងការសម្អាត។ | ☐ មាន<br>☐ មិនមាន | ៥ |
| | | ពិន្ទុសរុបទទួលបាន....... | ៣០ |

១.២. ការណែនាំស្ដីពីការអនុវត្តក្នុងបរិវេណមុខ និងក្នុងទីតាំងគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ

| ល.រ | សូចនាករនៃការអនុវត្ត | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១.២.១ | កំណត់ទិសដៅផ្ទុយគ្នាសម្រាប់ច្រកដែលអ្នកសិក្សាចូលទៅក្នុងសាលា និងពេលចេញមកវិញ ដោយមានការដាក់តាំងសញ្ញាច្បាស់លាស់។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.២.២ | មានបុគ្គលិកបណ្ដុះបណ្ដាលប្រចាំការ ឬបំពាក់ម៉ាស៊ីនត្រួតពិនិត្យកម្ដៅដោយស្វ័យប្រវត្តិ និងបញ្ជូនសញ្ញានៅច្រកចេញចូលដែលតម្រូវឱ្យមានការវាស់កម្ដៅមុនចូលឱ្យបានគ្រប់ៗគ្នា។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.២.៣ | មានបុគ្គលិកបណ្ដុះបណ្ដាលប្រចាំការ ឬបំពាក់ម៉ាស៊ីនបាញ់អាកុល ឬថ្នាំសម្លាប់មេរោគដោយស្វ័យប្រវត្តិស្របតាមស្តង់ដាត្រឹមត្រូវ នៅច្រកចេញចូល និងមានការលាងដៃ ឬឆ្លងកាត់ម៉ាស៊ីនសម្លាប់មេរោគគ្រប់ៗគ្នាមុននឹងចូលទៅក្នុងទីតាំងបរិវេណសិក្សា។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.២.៤ | មានបុគ្គលិកប្រចាំការ ឬស្លាកសញ្ញាណែនាំនិងមានការកត់ត្រាវត្តមាន ឬចុះឈ្មោះក្នុងប្រព័ន្ធ QR CODE ដើម្បីទប់ស្កាត់កូវីដ-១៩ (www.StopCovide19.gov.kh) របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់ជនគ្រប់រូបដែលចូលក្នុងទីតាំងបរិវេណសិក្សា។ | ☐ មាន<br>☐ មិនមាន | ៥* |
| ១.២.៥ | តុអង្គុយសម្រាប់អ្នកសិក្សាក្នុងបន្ទប់សិក្សា ទីកន្លែងអនុវត្ត និងហ្វឹកហាត់ការងារ មានរក្សាគម្លាតសុវត្ថិភាព ១,៥០ម៉ែត្រឡើងទៅ និងមានកំណត់ចំនួនអ្នកសិក្សាក្នុងថ្នាក់ដោយមិនឱ្យលើសពី២០នាក់ក្នុង០១ថ្នាក់។ មានការអនុវត្តតាមគន្លាតសុវត្ថិភាព និងវិធានការសុខាភិបាលក្នុងការរៀបចំតុកៅអីអង្គុយសម្រាប់អ្នកសិក្សាលើសពី ២០ នាក់ ក្នុងករណីបន្ទប់មានទំហំធំទូលាយ។ | ☐ មាន<br>☐ មិនមាន | ១០* |
